## ត្រាស់បង្គាប់

**មាត្រា ១.-**

តែងតាំងឯកឧត្តម **នួន សំភា** ជាទីប្រឹក្សាឯកឧត្តម **ញឹក ប៊ុនឆៃ** អនុប្រធានទី ២ នៃព្រឹទ្ធសភា មានឋានៈស្មើ **អគ្គនាយក** ជំនួសលោក **ចៅ សុខុន** ។

**មាត្រា ២.-**

លោក **នួន សំភា** ស្ម័គ្រចិត្តបំរើការងារដោយពុំយកប្រាក់បៀវត្ស ។

**មាត្រា ៣.-**

ប្រធានព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០១

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

## ព្រះរាជក្រឹត្យ នស/រកត/០២០១/០៣៦

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

☆☆☆

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១០ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន
- បានឃើញអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩២
- តាមសេចក្តីក្រាបបង្គំស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០១

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### ត្រាស់បង្គាប់

**មាត្រា ១.-**

ព្រះរាជក្រឹត្យនេះកំណត់ការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី មានអក្សរកាត់ថា **ក.ជ.ក.ស** ។ **ក.ជ.ក.ស** ជាយន្តការសំរបសំរួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាល លើបញ្ហាដែលទាក់ទងដល់ការលើកកំពស់ស្ថានភាព តួនាទីរបស់ស្ត្រី និង សុខុមាលភាពសង្គមស្ត្រីកម្ពុជា សំដៅកាត់បន្ថយ ឈានទៅលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រី និងអំពើហិង្សាលើស្ត្រី ។

## ជំពូកទី ២

## សមាសភាព

**មាត្រា ២.-**

**ក.ជ.ក.ស** មានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- សម្តេចព្រះរាជអគ្គមហេសី | ព្រះប្រធានកិត្តិយស |
| ២- នាយករដ្ឋមន្ត្រី | អនុប្រធានកិត្តិយស |
| ៣- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ជាប្រធាន |
| ៤- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១ រូប អនុប្រធាន |

| | | | |
|---|---|---|---|
| ៥- | រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | ០១រូប | អនុប្រធាន |
| ៦- | រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ០១រូប | សមាជិក |
| ៧- | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ០១រូប | សមាជិក |
| ៨- | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | សមាជិក |
| ៩- | រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា | ០១រូប | សមាជិក |
| ១០- | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | ០១រូប | សមាជិក |
| ១១- | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១រូប | សមាជិក |
| ១២- | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ០១រូប | សមាជិក |
| ១៣- | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ០១រូប | សមាជិក |
| ១៤- | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១រូប | សមាជិក |
| ១៥- | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ០១រូប | សមាជិក |
| ១៦- | រដ្ឋលេខាធិការក្រសួងពត៌មាន | ០១រូប | សមាជិក |
| ១៧- | រដ្ឋលេខាធិការក្រសួងផែនការ | ០១រូប | សមាជិក |
| ១៨- | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | ០១រូប | សមាជិក |
| ១៩- | អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ | ០១រូប | សមាជិក |

**មាត្រា ៣.-**

**គ.ជ.គ.ស** មានសិទ្ធិទំនាក់ទំនងបន្ថែមជាមួយស្ថាប័ន ក្រសួងនានា អង្គការសង្គមស៊ីវិល អង្គការអន្តរជាតិ ប្រទេសផ្តល់ជំនួយដទៃទៀតដែលពុំបានចែងក្នុងសមាសភាពនេះ តាមការយល់ឃើញដើម្បីចូលរួមប្រជុំផ្តល់យោបល់ ឬធ្វើជាអ្នកសង្កេតការ តាមការអញ្ជើញរបស់ **គ.ជ.គ.ស** ។

## ជំពូកទី ៣

## ភារកិច្ច រចនាសម្ព័ន្ធ និង ការប្រព្រឹត្តិទៅរបស់ គ.ជ.ក.ស

**មាត្រា ៤.-**

**គ.ជ.ក.ស** មានភារកិច្ច ដូចតទៅ :

- ជួយរាជរដ្ឋាភិបាលក្នុងការសំរបសំរួល តាមដាន វាយតំលៃការអនុវត្តន៍ និងផ្តល់អនុសាសន៍ក្នុងគោលបំណងគាំទ្រ និងជំរុញការអនុវត្តន៍គោលនយោបាយ ច្បាប់ បទបញ្ជា និងវិធានការដែលទាក់ទងដល់ការ លើកកំពស់ស្ថានភាព តួនាទី និងសុខុមាលភាពសង្គមស្ត្រីកម្ពុជា ។

- ជួយរាជរដ្ឋាភិបាលក្នុងការតាមដានលើការអនុវត្តន៍សន្ធិសញ្ញាអន្តរជាតិនានា ពាក់ព័ន្ធទៅនឹងសិទ្ធិនារី និងលើការអនុវត្តន៍ច្បាប់ដែលទាក់ទងដល់ការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស លើបទបញ្ញត្តិច្បាប់នានាដែលមានទំនាក់ទំនងដល់ស្ថានភាពស្ត្រី ដើម្បីផ្តល់យោបល់អនុសាសន៍ ឬ សុំធ្វើវិសោធនកម្មតាមករណីជាក់ស្តែង ដើម្បីធ្វើឱ្យស្ថានភាពស្ត្រីកាន់តែប្រសើរឡើង ។

- ពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍ជាតិ ស្តីពីការអនុវត្តន៍អនុសញ្ញា CEDAW និងស្តីពីស្ថានភាពនារី ជូនរាជរដ្ឋាភិបាលសំរេច ដើម្បីធ្វើជូនអង្គការសហប្រជាជាតិ ។

- រៀបចំរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាពដែលក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីបានបំពេញ ដើម្បីធ្វើជូនរាជរដ្ឋាភិបាល ។

- ពិនិត្យ និងសំរេចលើបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.ក.ស**

- ទទួលភារកិច្ចផ្សេងៗទៀតតាមសំណូមពររបស់រាជរដ្ឋាភិបាល

**មាត្រា ៥.-**

**គ.ជ.ក.ស** មាន :

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅទីស្តីការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ។

អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការមួយរូប ដែលមានឋានៈស្មើអនុរដ្ឋលេខាធិការ មានអគ្គលេខាធិការរងពីររូប និងមានបុគ្គលិកផ្ទាល់ជាអចិន្ត្រៃយ៍មួយចំនួន ដែលជាបុគ្គលិកមានស្រាប់របស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ។ អគ្គលេខាធិការ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៦.-**

**គ.ជ.ក.ស** អាច :

- បង្កើតអនុគណៈកម្មការជំនាញ មានសមាសភាពទាំងពីរភេទ ដែលជាមន្ត្រីមានក្របខ័ណ្ឌស្រាប់ជាជំនួយការ ដើម្បីអនុវត្តតាមតំរូវការ ភារកិច្ច ដូចដែលមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ ។
- មានទីប្រឹក្សាជាតិ និងអន្តរជាតិមួយចំនួនដែលមានសមាសភាពជាអ្នកជំនាញ ដើម្បីជួយ និង **គ.ជ.ក.ស** អគ្គលេខាធិការដ្ឋាន ។

**មាត្រា ៧.-**

**គ.ជ.ក.ស** ត្រូវជួបប្រជុំជាសាមញ្ញរៀងរាល់ត្រីមាស ក្នុងករណីមានការចាំបាច់ **គ.ជ.ក.ស អាចប្រជុំជាវិសាមញ្ញតាមការកោះប្រជុំ និងក្រោមអធិបតីភាពរបស់រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ដែលជាប្រធាន ។**

ក្នុងមួយឆ្នាំម្តង **គ.ជ.ក.ស** ត្រូវធ្វើការបូកសរុបរាយការណ៍ជូនអង្គប្រជុំ **គ.ជ.ក.ស** ក្រោមព្រះរាជាធិបតីភាពរបស់សម្តេចព្រះរាជអគ្គមហេសី ព្រះប្រធានកិត្តិយស និងសម្តេចនាយករដ្ឋមន្ត្រី អនុប្រធានកិត្តិយស លើលទ្ធផលនៃការអនុវត្តន៍ លើកម្មវិធីការងារដែលត្រូវសំរបសំរួល និងអនុសាសន៍ ដែល **គ.ជ.ក.ស** ត្រូវដាក់ចេញ ។

**មាត្រា ៨.-**

**គ.ជ.ក.ស** មានបទបញ្ជាផ្ទៃក្នុង និងត្រាមួយដោយឡែករបស់ខ្លួន ។

## ជំពូកទី ៤
## ថវិកា

**មាត្រា ៩.-**

**ក.ជ.ក.ស** មានថវិកាផ្ទាល់ខ្លួនដោយឡែក ត្រូវជាឧបសម្ព័ន្ធថវិការបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ។ ថវិកានេះមានប្រភពទុនពីរ :

- ថវិកាជាតិ
- ជំនួយឧបត្ថម្ភអន្តរជាតិ ប្រទេសផ្តល់អំណោយ សប្បុរសជនជាតិ ឬបរទេស ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១.-**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្ថលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន

ហត្ថលេខា

**មូរ សុខហួរ**